01452872

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 04 / 2017
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E319/68/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បង្ហាញថ្មីៗពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២

១. នៅក្នុងសំណើសុំដាក់បង្ហាញឯកសារ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលសាក្សីទាំងនោះបានផ្តល់សក្ខីកម្មក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២ (ឯកសារ E319/68 កថាខណ្ឌ ៣)។ មិនមានភាគីណាមួយដាក់សារណាឆ្លើយតបទៅនឹងសំណើនេះទេ។

២. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកពីការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។ វាជាប្រយោជន៍ក្នុងការស្វែងរកការពិតដែលអង្គជំនុំជម្រះ និងភាគីអាចចូលពិនិត្យមើលចម្លើយទាំងអស់របស់

ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ដែលនឹងមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E421/4 កថាខណ្ឌ ១២)។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការអនុវត្តនេះក៏ប្រើប្រាស់ចំពោះចម្លើយដែលត្រូវបានធ្វើឡើងបន្ទាប់ពីសាក្សីនោះបានផ្ដល់សក្ខីកម្មរួចហើយផងដែរ ដើម្បីអាចឱ្យអង្គជំនុំជម្រះ និងភាគី វិភាគបានពេញលេញពីភាពអាចជឿជាក់បាន ដោយផ្អែកទៅលើថា តើចម្លើយរបស់សាក្សីទាំងនោះស្ថិតស្ថេរបានកម្រិតណា។ ហេតុដូចនេះហើយ ការទទួលយកចម្លើយរបស់សាក្សីបន្ទាប់ពីសាក្សីនោះបានមកផ្ដល់សក្ខីកម្ម គឺជាប្រយោជន៍នៃការស្វែងរកការពិតផងដែរ។

៣. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន ២ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ និងដាក់ជាលេខឯកសារដូចតទៅ៖ ឯកសារ E3/10801 និងឯកសារ E3/10802 (ឯកសារ E319/68.2)។

៤. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/68។